រាជបណ្ឌិត្យសភាកម្ពុជា

# ការលើកកម្ពស់ភាពសុខដុមនៃសង្គមមនុស្ស

## Promoting Harmony of Human Society

ឈត ប៊ុនថន

និក្ខេបបទបណ្ឌិតទស្សនវិជ្ជា

ឯកទេស ៖ ទស្សនវិជ្ជា

២០១២

Scanned by CamScanner

រាជបណ្ឌិត្យសភាកម្ពុជា

# ការលើកកម្ពស់ភាពសុខដុមនៃមនុស្ស

# Promoting Harmony of Human Society

ឈត ប៊ុនថន

និក្ខេបបទបណ្ឌិតទស្សនវិជ្ជា

ឯកទេស ៖ ទស្សនវិជ្ជា

សាស្ត្រាចារ្យណែនាំ៖ បណ្ឌិតសភាចារ្យ ខ្លូត ធីតា

២០១២

# មាតិកា

ទំព័រ


ការឧទ្ទិសស្នាដៃ ---------------------------------------------------------------iv
សេចក្តីថ្លែងអំណរគុណ ---------------------------------------------------------------v
អំណះអំណាង ---------------------------------------------------------------vi
អក្សរកាត់ --------------------------------------------------------------- vii
មូលន័យសង្ខេប ---------------------------------------------------------------ix
សង្ខេបនិក្ខេបបទ ---------------------------------------------------------------xiii
អារម្ភកថា --------------------------------------------------------- xxxvii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ--------------------------------------------------------------- ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ --------------------------------------------------------------- ២
៣. គោលបំណងនៃការស្រាវជ្រាវ --------------------------------------------------------------- ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ--------------------------------------------------- ៣
៥. វិធីសាស្ត្រស្រាវជ្រាវ --------------------------------------------------------------- ៣
៦. សារសំខាន់នៃការស្រាវជ្រាវ ---------------------------------------------------------------៤
៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ ---------------------------------------------------------------៤


## ជំពូកទី១
## ទស្សនវិជ្ជាសីលធម៌ និងភាពសុខដុម


១.១ ទស្សនវិជ្ជាសីលធម៌ ---------------------------------------------------------------៦
១.២ សាកលភាពនៃសីលធម៌ --------------------------------------------------------------- ១៧
១.២.១ សេចក្តីប្រកាសឆ្ពោះទៅរកសាកលភាពនៃសីលធម៌ ---------------------------------------២១
១.២.២ ការណែនាំសំខាន់ៗទាំងបួនដែលមិនអាចបដិសេធបាន ----------------------------- ២៨
១.៣ ភាពសុខដុម ---------------------------------------------------------------៣៥
១.៣.១ មូលដ្ឋាននៃការកសាងភាពសុខដុម ---------------------------------------------------៣៨

ក. សាសនា ---------------------------------------------------------------------- ៣៨
ខ. ទំនៀមទម្លាប់ប្រពៃណី ---------------------------------------------------------- ៤៩
គ. ច្បាប់ ---------------------------------------------------------------------- ៥១
ឃ. សិទ្ធិមនុស្ស ------------------------------------------------------------- ៧៨
ង. សីលធម៌ ---------------------------------------------------------------------- ៨១
ច. នយោបាយ ------------------------------------------------------------------- ៨៦
១.៣.២ សារសំខាន់នៃភាពសុខដុម ------------------------------------------------ ៨៨

## ជំពូកទី២
## ការលើកកម្ពស់ភាពសុខដុមរបស់សង្គមមនុស្ស

២.១ ភាពសុខដុមនៃសង្គមមនុស្សតាមរយៈផ្លូវកណ្ដាល ------------------------------ ៩០
២.១.១ បញ្ញត្តិស្ដីពីសីលធម៌ផ្លូវកណ្ដាលក្នុងបរិបទសង្គមខ្មែរ -------------------------- ៩០
២.១.២ សីលធម៌ផ្លូវកណ្ដាលក្នុងទស្សនវិជ្ជា ------------------------------------------ ៩៤
២.១.៣ សីលធម៌ផ្លូវកណ្ដាលក្នុងព្រះពុទ្ធសាសនា ------------------------------------- ៩៨
២.២ ផ្លូវកណ្ដាលក្នុងបរិបទអប់រំ ----------------------------------------------------- ១០៥
២.២.១ ទ្រឹស្ដីឯកការូបនីយកម្មនៃការអប់រំ --------------------------------------------- ១០៥
២.២.២ ទស្សនវិជ្ជាអប់រំព្រះពុទ្ធសាសនា ------------------------------------------------ ១១៤
២.២.៣ ទស្សនវិជ្ជាអប់រំរបស់ទស្សនវិទូនិងនិកាយមួយចំនួនទៀត ------------------------ ១២០
២.២.៤ ការវាយតម្លៃទ្រឹស្ដីអប់រំផ្អែកលើគំនិតឯកការូបនីយកម្ម ---------------------------- ១៤២
២.៣ ផ្លូវកណ្ដាលក្នុងការគ្រប់គ្រងរដ្ឋ ------------------------------------------------- ១៤៦
២.៤ ផ្លូវកណ្ដាលក្នុងបរិបទពាណិជ្ជកម្ម ------------------------------------------------ ១៧៣
២.៥ ភាពសុខដុមតាមរយៈយន្តការមូលដ្ឋានផ្សេងទៀត ------------------------------- ១៧៥
២.៥.១ អង្គការសហប្រជាជាតិ ----------------------------------------------------------- ១៧៥
២.៥.២ អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង ------------------------------------------- ១៧៨
២.៥.៣ សហភាពអឺរ៉ុប ------------------------------------------------------------------ ១៨០
២.៥.៤ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ------------------------------------------------ ១៨២
២.៥.៥ តុលាការយុត្តិធម៌អន្តរជាតិ -------------------------------------------------------- ១៨៧
២.៥.៦ ស្ថានទូត ---------------------------------------------------------------------- ១៩០
២.៥.៧ អង្គការសិទ្ធិមនុស្ស -------------------------------------------------------------- ១៩៣
២.៥.៨ សភាសាសនាពិភពលោក -------------------------------------------------------- ១៩៧
២.៥.៩ សហព័ន្ធសន្តិភាពសាកលលោក ------------------------------------------------- ២១០
២.៥.១០ រង្វាន់ណូបែលសន្តិភាព ------------------------------------------------------ ២១៤

# ជំពូកទី៣
# សុខដុមនីយកម្មក្នុងសង្គមខ្មែរ


៣.១ កម្រិតបុគ្គល ----------------------------------------------------------------------------២២១

៣.១.១ កាតព្វកិច្ចចំពោះខ្លួនឯង----------------------------------------------------------------២២២

៣.១.២ កាតព្វកិច្ចចំពោះអ្នកដទៃ ---------------------------------------------------------------២២៥

៣.១.៣ កាតព្វកិច្ចចំពោះបរិស្ថាន ---------------------------------------------------------------២២៦

៣.២ កម្រិតគ្រួសារ ----------------------------------------------------------------------------២៣៥

៣.២.១ ករណីយកិច្ចរបស់គូស្វាមីភរិយាចំពោះគ្រួសារ ----------------------------------------២៣៦

៣.២.២ សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្ដាយចំពោះកូន ---------------------------------------២៣៧

៣.២.៣ អំណាចគ្រួសារ -------------------------------------------------------------------------២៣៨

៣.២.៤ កាតព្វកិច្ចរបស់កូនចំពោះឪពុកម្ដាយ-----------------------------------------------------២៣៩

៣.៣ កម្រិតស្ថាប័នរដ្ឋ -------------------------------------------------------------------------២៤០

៣.៣.១ ស្ថាប័ននីតិបញ្ញត្តិ -----------------------------------------------------------------------២៤១

៣.៣.២ ស្ថាប័ននីតិប្រតិបត្តិ ---------------------------------------------------------------------២៤៣

៣.៣.៣ ស្ថាប័នតុលាការ -----------------------------------------------------------------------២៤៨

៣.៤ ប្រព័ន្ធផ្សព្វផ្សាយ ------------------------------------------------------------------------២៥១

៣.៥ វិស័យឯកជន ---------------------------------------------------------------------------២៥៣

៣.៦ វិស័យសង្គមស៊ីវិល -----------------------------------------------------------------------២៦៣

៣.៧ វិស័យសាសនា --------------------------------------------------------------------------២៦៧

៣.៨ គណបក្សនយោបាយ ---------------------------------------------------------------------២៧៣

៣.៩ កត្តាមូលដ្ឋានដែលនាំឱ្យសង្គមខ្មែរមានទំនាស់ និងដំណោះស្រាយ-------------------------២៧៨

៣.៩.១ កត្តាមូលដ្ឋានដែលនាំឱ្យសង្គមខ្មែរមានទំនាស់------------------------------------------២៧៨

៣.៩.២ យន្តការដោះស្រាយទំនាស់ក្នុងសង្គមខ្មែរ ----------------------------------------------២៨២

សន្និដ្ឋាន --------------------------------------------------------------------------------------២៩៣

គន្ថនិទ្ទេស ------------------------------------------------------------------------------------៣០៥

ឧបសម្ព័ន -------------------------------------------------------------------------------------៣១៣

សទ្ទានុក្រម ------------------------------------------------------------------------------------៣២៦

# មូលន័យសង្ខេប

បើទោះបីជាមានការប៉ុនប៉ងនានារបស់ទស្សនវិទូ សង្គមវិទូ និងអ្នកប្រាជ្ញដទៃទៀតដើម្បីស្វែងរកមធ្យោបាយនានាឆ្ពោះទៅរកសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការចុះសម្រុងគ្នាក៏ដោយ ក៏ភាពសុខដុមសាកលយូរអង្វែងនៅតែមិនទាន់ទទួលបានជោគជ័យពេញលេញតាមបំណងប្រាថ្នារបស់មនុស្សនៅឡើយ។ ផ្ទុយទៅវិញ ដោយសារតែអំពើអសីលធម៌ អំពើអមនុស្សធម៌ ការលោភលន់ និងការប្រកួតប្រជែងស្ទើរគ្រប់វិស័យដែលមិនផ្អែកលើគោលការណ៍សីលធម៌ នាំឲ្យសង្គមមនុស្សទាំងមូលលេចឡើងនូវសភាពបែកបាក់សាមគ្គី ការដណ្តើមអំណាច ការដណ្តើមទ្រព្យសម្បត្តិ ការដណ្តើមទីផ្សារ សង្គ្រាម ការរត់ប្រណាំងសព្វាវុធ។ល។ ដែលមហិច្ឆតាទាំងនេះនិងចន្លោះនៃមនោគមវិជ្ជានយោបាយផ្ទុយគ្នា បានរុញច្រានសង្គមមនុស្សឲ្យធ្លាក់ទៅក្នុងសង្គ្រាមរ៉ាំរ៉ៃ និងទទួលរងការខ្ទេចខ្ទាំទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងស្មារតី ហិនហោចទ្រព្យសម្បត្តិ និងបាត់បង់អាយុជីវិតមនុស្សរាប់លាននាក់នៅពាសពេញពិភពលោក។

ដោយពិនិត្យឃើញបែបនេះហើយ ទើបជំរុញឲ្យខ្ញុំជ្រើសរើសយកប្រធានបទមួយដែលមានចំណងជើងថា៖ «ការលើកកម្ពស់ភាពសុខដុមនៃសង្គមមនុស្ស»មកសិក្សាស្រាវជ្រាវ។ ការលើកឡើងនូវប្រធានបទនេះគឺមានបំណងរួមចំណែកក្នុងការស្តារឡើងវិញនូវតម្លៃសីលធម៌ និងរកឲ្យឃើញនូវចំណុចរួមនៅក្នុងនិយាមសង្គមផ្សេងៗ ដើម្បីលើកកម្ពស់ភាពសុខដុមសាកលនៅក្នុងសង្គមមនុស្ស។ ភាពសុខដុមសាកលគឺជាគោលបំណងសំខាន់បំផុតរបស់សង្គមមនុស្ស ដែលទស្សនវិទូ សង្គមវិទូ និងមនុស្សទូទៅដែលស្រឡាញ់សន្តិភាព សន្តិសុខនិងអភិវឌ្ឍន៍ ខិតខំស្វែងរកតាំងពីយូរយារណាស់មកហើយរហូតមកដល់បច្ចុប្បន្ន។ ការស្វែងរកនេះទើបតែទទួលបានជោគជ័យស្តួចស្តើងប៉ុណ្ណោះ ដែលមិនទាន់សមស្របនឹងបំណងប្រាថ្នារបស់សង្គមមនុស្សទាំងមូលនៅឡើយ ដោយសារតែមានឧបសគ្គជាច្រើនដូចជា ភាពមានះ ភាពជ្រុលនិយម ឬភាពដាច់ខាត ភាពល្ងង់ខ្លៅ និងការលោភលន់របស់បុគ្គល ឬនិកាយនីមួយៗ និងការមិនឲ្យតម្លៃលើសារសំខាន់នៃភាពសុខដុមសាកលជាដើម។ ហេតុនេះហើយបានជាភាពសុខដុមសាកលនៅតែជាប្រធានបទមួយយ៉ាងសំខាន់ និងរឹតតែចាំបាច់ថែមទៀតនៅក្នុងសម័យសាកលភាវូបនីយកម្ម ដែលពិភពលោកទាំងមូលកំពុងរត់ប្រណាំងខាងសម្ភារ បច្ចេកវិទ្យា សេដ្ឋកិច្ច ចំណេះដឹង ប្រណីតភាព និងការប្រកួតប្រជែងលើវិស័យផ្សេងៗទៀត មានជាអាទិ៍ ការប្រកួតប្រជែងខាងយោធា នយោបាយ សព្វាវុធ ការដណ្តើមធនធានធម្មជាតិ វត្ថុធាតុដើម និងទីផ្សារ ជាដើម។ បច្ចុប្បន្នដោយសារតែកង្វះភាពសុខដុមសាកលនេះហើយ បានជាយើងសង្កេតឃើញលេចឡើងនូវបញ្ហាជាច្រើនរាប់មិនអស់ ដូចជា អំពើហិង្សានៅក្នុងគ្រួសារ ជម្លោះផ្សេងៗនៅក្នុងសហគមន៍ជាតិនិងអន្តរជាតិ មានដូចជាជម្លោះបញ្ហាព្រំដែន ជម្លោះសាសនា ជម្លោះវប្បធម៌ ជម្លោះសេដ្ឋកិច្ច ជម្លោះនយោបាយ ការរើសអើងជាតិសាសន៍ ការរើសអើងភេទ ការរើសអើងពណ៌សម្បុរ និងការរើសអើងមនោគមវិជ្ជា ជាដើម។ កត្តាទាំងនេះបានជំរុញឲ្យទស្សនវិទូ សង្គមវិទូ និងអ្នកប្រាជ្ញដទៃទៀតដែលស្រឡាញ់សន្តិភាព សន្តិសុខ ភាពចុះសម្រុងគ្នានិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ខិតខំរិះរកវិធីផ្សេងៗដើម្បីឆ្ពោះទៅរកសុខដុមនីយកម្មសាកល។

# ABSTRACT

Even though philosophers, sociologists, and other scholars have tried to find the ways forwards peace, security, social order, justice, and sustainable development, however, long global harmony does not completely succeed and respond to our desire yet. In contrast, because of immoral actions, inhuman acts, greed, and competition of almost fields do not base on moral principles cause the whole human society appears of the break up of social solidarity, deputing for power, wealth, marketing or clients; in addition the world spread of wars and weapon race, etc.; which these ambition and the current of the opposite political ideologies cause the entire human society faces with wars for long time, and damages of physical and spiritual infrastructures, destroy the wealth, injure and kill millions people in the world.

The situation and feature have been mentioned above encourage me to choose the topic of "PROMOTING HARMONY OF HUMAN SOCIETY" for my PhD research. The purpose of this research is to contribute in rebuilding the moral value and find out the common elements in the social norms for promoting global harmony in the total human society. Global harmony is the most important for human society which philosophers, sociologists, and other people who love peace, security, and development have attempted to find out since long time until now. Up to the present this purpose does not significantly achieve and respond to the society's aspiration. This for the reason that many obstacles such as personal arrogance, extreme, ignorance, and selfish in the term of individual and social group; in addition because of most people do not encourage the significant of global harmony.

So, the global harmony is still the fundamental topic and it is more necessary in the globalization that the world faces with the contesting of materials, technologies, economics, knowledge, richness, and other competition in the fields of politics, military, weapon, natural resources, raw materials, and marketing or customers. In the present, because of the lack of global harmony we have seen innumerous problems happen in the world like domestic violence, national community conflicts and international community disagreements related to borders, religions, cultures, economics, politics, discrimination, and ideologies. These problems have persuaded philosophers, sociologists, and other scholars who love peace, security, sustainable development and harmony do their best to search for the ways forward global harmonization.

According to the philosophical analysis we can conclude that there are some ways that has been used for harmonizing human society as whole such as practice of customs, traditions, religions, laws, and morality etc. These means have been used for long time; nevertheless, human society's harmony has not been significantly complete yet because these methods tend to individual, bias, and extreme. Furthermore, sometime, harmonizing of one group or one nation is achieved by exploration, threatening, aggressing over another group or nation. This kind of achievement does not accordance with philosophical reasoning and wisdom. The reason why human society does not significantly obtain the global harmonization is because of the global basic norm or standard has not been find out and the lack of unity in practicing this global basic norm in coexistences. The global basic norm or standard is called global ethic; apart from this we also have practice the middle way and human rights as well.

Under the consideration of this situation, promote me as a person who interested in global peace and sustainable development to choose my topic mentioned above in order to check, analyze, criticize and valuate social norms like customs, traditions, religions, moralities and other laws in order to select the strength, weakness, particularity, commonness, goodness, badness, absoluteness, and middle way etc. Moral philosophy is the central subject which is used to reflect all the elements have listed above in the purpose of searching for consensus, global ethic, common value, global perspectives, and middle way, which some scholars called the Golden Mean or Golden Rule of life as bridge for leading to find out the global harmonization, world peace and sustainable development. The main purpose of this research is to contribute in judgment of the means and mechanisms in order to bring Khmer society and the human society as whole to achieve the true harmony.

The whole dissertation divides into three chapters; the first chapter is about moral philosophy and harmony. The second is the promoting harmony in human society, and the third is harmonization in Khmer society. The main issues in the dissertation are: 1. the social norms have existed for long time, why harmony does not exist in society? 2. Are there any basic mechanisms and means that can be used to encourage the human society to obtain extended global harmonization? At the end, this dissertation shows the challenges and resolution in pushing society forwards peace, security, social order, justice, true love, human rights, common development and global harmonization.

# សេចក្ដីសង្ខេបនិក្ខេបបទ

ទោះបីជាសង្គមមនុស្ស មានអត្ថិភាពនៅលើភពផែនដីនេះអស់រយៈពេលរាប់រយពាន់ឆ្នាំមកហើយក៏ដោយ ក៏វានៅតែប្រឈមមុខនឹងការបែកបាក់ ជម្លោះ ការរំលោភបំពាន និងការគំរាមកំហែងពីមនុស្សអាក្រក់ ជនល្មោភសង្គ្រាម និងជនផ្ដាច់ការ ជាដើម។ ការប៉ុនប៉ងនានារបស់ទស្សនវិទូ សង្គមវិទូ និងអ្នកប្រាជ្ញដទៃទៀត ដើម្បីស្វែងរកមធ្យោបាយនានាឆ្ពោះទៅរកសន្តិភាព សន្តិសុខ ការចុះសម្រុងគ្នា សណ្ដាប់ធ្នាប់ យុត្តិធម៌ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសុខដុមសាកលយូរអង្វែង នៅតែមិនទាន់ទទួលបានជោគជ័យពេញលេញតាមបំណងប្រាថ្នានៅឡើយ។

ផ្ទុយទៅវិញ ដោយសារតែអំពើអសីលធម៌ អំពើអមនុស្សធម៌ ការលោភលន់ និងការប្រកួតប្រជែងស្ទើរគ្រប់វិស័យដែលមិនផ្អែកលើគោលការណ៍សីលធម៌ នាំឱ្យសង្គមមនុស្សទាំងមូលលេចឡើងនូវសភាពបែកបាក់សាមគ្គី ការដណ្ដើមអំណាច ការដណ្ដើមទ្រព្យសម្បត្តិ ការដណ្ដើមទីផ្សារ សង្គ្រាម ការរត់ប្រណាំងសព្វាវុធ។ល។ ដោយសារមហិច្ឆតាទាំងនេះ និងដោយសារចរន្តនៃមនោគមវិជ្ជានយោបាយផ្ទុយគ្នា បានរុញច្រានសង្គមមនុស្សឱ្យធ្លាក់ទៅក្នុងសង្គ្រាមរ៉ាំរ៉ៃ និងទទួលរងការខូចខាតទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងស្មារតី ហិនហោចទ្រព្យសម្បត្តិ និងបាត់បង់អាយុជីវិតមនុស្សរាប់លាននាក់នៅពាសពេញពិភពលោក។

នៅដើមសតវត្សទី២១ ដែលជាសម័យសាកលភាវូបនីយកម្ម ការគិតរបស់មនុស្ស របកគំហើញ និងការបង្កើតថ្មីខាងវិទ្យាសាស្ត្របានឈានដល់កម្រិតមួយខ្ពស់ហួសពីការស្មានរបស់មនុស្ស។ ការអភិវឌ្ឍថ្មីនេះបានរួមចំណែកធ្វើឱ្យសង្គមមនុស្សទទួលបានភាពងាយស្រួលក្នុងការរស់នៅ ផាសុកភាព ប្រណីតភាព ភាពងាយស្រួល ប្រសិទ្ធភាព និងភាពឆាប់រហ័សក្នុងការបំពេញការងារ ដំណើរការផលិតកម្ម ទំនាក់ទំនង ការធ្វើដំណើរ ការដឹកជញ្ជូន និងការព្យាបាលជំងឺ ជាដើម។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏លក្ខណៈទាំងអស់នេះគ្រាន់តែអាចបំពេញសេចក្ដីរីករាយខាងវិញ្ញាណ ឬសេចក្ដីសុខផ្នែកខាងក្រៅប៉ុណ្ណោះ។ ផ្ទុយទៅវិញ ការរីកចម្រើនថ្មីនេះក៏ជាសក្ដានុពលយ៉ាងធំធេងក្នុងការធ្វើឱ្យស្រុតចុះនូវតម្លៃសីលធម៌ គុណធម៌ និងធ្វើឱ្យមានការបាត់បង់ជំនឿលើគ្នាទៅវិញទៅមកផងដែរ។

ដោយពិនិត្យឃើញបែបនេះហើយ ទើបជំរុញឱ្យខ្ញុំជ្រើសរើសយកប្រធានបទមួយដែលមានចំណងជើងថា៖«ការលើកកម្ពស់ភាពសុខដុមនៃសង្គមមនុស្ស»។ ការលើកឡើងនូវប្រធានបទនេះ គឺមានបំណងរួមចំណែកក្នុងការស្ដារឡើងវិញនូវតម្លៃសីលធម៌ និងរកឱ្យឃើញនូវចំណុចរួមនៅក្នុងនិយាមសង្គមផ្សេងៗ ដើម្បីលើកកម្ពស់ភាពសុខដុមសាកលនៅក្នុងសង្គមមនុស្ស។

ភាពសុខដុមសាកល គឺជាគោលបំណងសំខាន់បំផុតរបស់សង្គមមនុស្ស ដែលទស្សនវិទូ សង្គមវិទូ និងមនុស្សទូទៅដែលស្រឡាញ់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍ ខិតខំស្វែងរកតាំងពីយូរយារណាស់មកហើយរហូតមកដល់បច្ចុប្បន្ន។ ការខិតខំស្វែងរកនេះទើបតែទទួលបានជោគជ័យស្ដួចស្ដើងប៉ុណ្ណោះ ដែលមិនទាន់សមស្របនឹងបំណងប្រាថ្នារបស់សង្គមមនុស្សទាំងមូលនៅឡើយ ដោយសារតែនៅមានឧបសគ្គជាច្រើន ដូចជា ភាពមានះ ភាពជ្រុលនិយម ឬភាពដាច់ខាត ភាពល្ងង់ខ្លៅ និងការលោភលន់របស់បុគ្គល ឬនិកាយនីមួយៗ និងការមិនឱ្យតម្លៃលើសារសំខាន់នៃសុខដុមរមនាសាកល ជាដើម។ អាស្រ័យហេតុនេះហើយបានជាសុខដុមសាកលនៅតែជាប្រធានបទមួយយ៉ាងសំខាន់ និងរឹតតែចាំបាច់ថែមទៀត

នៅក្នុងសម័យសាកលភាវូបនីយកម្ម ដែលពិភពលោកទាំងមូលកំពុងតែប្រណាំងខាងសម្ភារ បច្ចេកវិទ្យា សេដ្ឋកិច្ច ចំណេះដឹង ប្រណីតភាព និងការប្រកួតប្រជែងលើវិស័យផ្សេងៗទៀត មានជាអាទិ៍ ការប្រកួតប្រជែងខាងនយោបាយ យោធា សព្វាវុធ ការដណ្ដើមធនធានធម្មជាតិ វត្ថុធាតុដើម និងទីផ្សារ ជាដើម។ សុខដុមសាកលជួយឱ្យមានឯកភាព ឬការចុះសម្រុងគ្នានៅក្នុងគ្រួសារ សង្គមមនុស្សទូទៅ សហគមន៍ជាតិ សហគមន៍អន្តរជាតិ និងពិភពលោកទាំងមូល។ ប្រសិនបើគ្មានវាទេ ក្រុមសង្គមទាំងនោះនឹងមិនអាចស្ថិតស្ថេរ មានសន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពឡើយ។

បច្ចុប្បន្ន ដោយសារតែកង្វះសុខដុមសាកលនេះហើយ បានជាយើងសង្កេតឃើញលេចឡើងនូវបញ្ហាជាច្រើនរាប់មិនអស់ ដូចជា អំពើហិង្សានៅក្នុងគ្រួសារ ជម្លោះផ្សេងៗនៅក្នុងសហគមន៍ជាតិ និងអន្តរជាតិ មានដូចជា បញ្ហាជម្លោះព្រំដែន ជម្លោះសាសនា ជម្លោះវប្បធម៌ ជម្លោះសេដ្ឋកិច្ច ជម្លោះនយោបាយ ការរើសអើងជាតិសាសន៍ ការរើសអើងភេទ ពណ៌សម្បុរ និងមនោគមវិជ្ជា ជាដើម។ កត្តាទាំងនេះបានជំរុញឱ្យទស្សនវិទូ សង្គមវិទូ និងអ្នកប្រាជ្ញដទៃទៀតដែលស្រឡាញ់សន្តិភាព សន្តិសុខ ភាពចុះសម្រុងគ្នា និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ខិតខំរិះរកវិធីផ្សេងៗដើម្បីឆ្ពោះទៅរកសុខដុមនីយកម្មសាកល។

ឆ្លងតាមរយៈការវិភាគបែបទស្សនវិជ្ជា យើងបានមើលឃើញថា មានវិធីមួយចំនួនដែលសង្គមមនុស្សធ្លាប់បានអនុវត្តដើម្បីឆ្ពោះទៅរកសុខដុមនៅក្នុងសង្គម ដូចជា ការប្រតិបត្តិតាមទំនៀមទម្លាប់ ប្រពៃណី សាសនា សីលធម៌ និងច្បាប់ ជាដើម។ វិធីទាំងនេះសង្គមមនុស្សបានប្រើតាំងពីយូរយារណាស់មកហើយ ប៉ុន្តែសុខដុមសាកលពេញលេញរបស់សង្គមមនុស្សនៅតែមិនទាន់ទទួលបាននៅឡើយ ដោយសារតែវិធីទាំងនោះមានទំនោរទៅភាពដោយឡែក ភាពលម្អៀង ឬភាពដាច់ខាតរៀងៗខ្លួន។ មិនតែប៉ុណ្ណោះ ពេលខ្លះ សុខដុមរបស់ក្រុមមួយ សង្គមមួយ ឬជាតិមួយទទួលបានតាមរយៈការគាបសង្កត់ ការគំរាមកំហែង ឬការរំលោភបំពានទៅលើក្រុមសង្គម ឬជាតិសាសន៍ដទៃទៅវិញ។ មូលហេតុដែលសង្គមមនុស្សមិនទាន់ទទួលបានសុខដុមនីយកម្មសាកលពេញលេញនេះគឺពីព្រោះតែពួកគេមិនទាន់រកឃើញ និងមិនទាន់ឯកភាពគ្នាអំពីមូលដ្ឋានត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិតក្នុងការរួមរស់ជាមួយគ្នា មូលដ្ឋានដ៏ត្រឹមត្រូវនោះគឺសាកលភាពនៃសីលធម៌ សីលធម៌ផ្លូវកណ្ដាល និងគោលការណ៍រួមនេះឯង។

ដោយពិនិត្យឃើញសភាពដូច្នេះហើយ ទើបជំរុញឱ្យទស្សនវិទូ សង្គមវិទូ និងអ្នកប្រាជ្ញនានា ដែលស្រឡាញ់សុខដុមសាកល សន្តិភាពពិភពលោក និងការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព ចាប់ផ្ដើមពិនិត្យ វិភាគ រិះគន់ និងវាយតម្លៃលើនិយាមសង្គម ដូចជា ទំនៀមទម្លាប់ ប្រពៃណី សាសនា សីលធម៌ និងច្បាប់ផ្សេងៗដើម្បីពិនិត្យមើលចំណុចខ្លាំង ចំណុចខ្សោយ ភាពដោយឡែក ភាពរួម ចំណុចល្អ ចំណុចមិនល្អ ភាពដាច់ខាត និងផ្លូវកណ្ដាល ជាដើម ក្នុងបំណងរកឱ្យឃើញសាកលភាពនៃសីលធម៌ ដែលជាមូលដ្ឋានដ៏សំខាន់នេះ។ ទស្សនវិជ្ជាសីលធម៌ ជាមុខវិជ្ជាសំខាន់បំផុត ដែលគេប្រើប្រាស់ធ្វើជាប្រទីបសម្រាប់ឆ្លុះបញ្ចាំងមើលលក្ខណៈទាំងអស់ខាងលើនេះ ក្នុងគោលបំណងស្វែងរកចំណុចរួមគ្នា សីលធម៌សាកល តម្លៃរួម ទស្សនវិស័យរួមនិងផ្លូវកណ្ដាល ដែលអ្នកប្រាជ្ញមួយចំនួនហៅថាមធ្យោបាយមាស ឬច្បាប់មាសនៃជីវិត ដើម្បីធ្វើជាស្ពានឆ្លងទៅរកសុខដុមនីយកម្មសាកល សន្តិភាពពិភពលោក និងការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព។

ការស្រាវជ្រាវលើប្រធានបទដែលមានចំណងជើងថា៖«ការលើកកម្ពស់សុខដុមនៃសង្គមមនុស្ស» ផ្តោតទៅលើបញ្ហាមួយចំនួនដូចខាងក្រោម៖

-និយាមសង្គម មានដូចជា សាសនា ប្រពៃណី ទំនៀមទម្លាប់ សីលធម៌ និងច្បាប់រដ្ឋ ជាដើម មានអត្ថិភាពតាំងពីយូរលង់មកហើយនៅក្នុងសង្គមមនុស្ស តើហេតុអ្វីបានជាសង្គមមនុស្ស នៅតែមិនទាន់ទទួលបានសុខដុមរមនាពេញលេញនៅឡើយ?

-តើមានមូលដ្ឋាន យន្តការ និងវិធីអ្វីខ្លះដែលអាចធ្វើឱ្យសង្គមមនុស្សទទួលបានសុខដុមនីយកម្ម សាកលយូរអង្វែង?

គោលបំណងសំខាន់នៃការស្រាវជ្រាវនេះគឺ ចង់រួមចំណែកស្វែងរកវិធី និងយន្តការនានាដើម្បីជំរុញឱ្យសង្គមមនុស្សទូទៅ ក៏ដូចជាសង្គមខ្មែរឈានទៅរកសុខដុមនីយកម្មពិតប្រាកដ។ ដើម្បីអាចឈានទៅសម្រេចគោលបំណងនេះបាន យើងត្រូវតែរកឱ្យឃើញនូវឧបសគ្គ និងមូលហេតុនានាដែលរារាំងសុខដុមនីយកម្មសាកលកន្លងមក និងត្រូវរកឱ្យឃើញនូវវិធី និងយន្តការថ្មីៗទៀត ដែលរួមចំណែកក្នុងការនាំពិភពលោកឆ្ពោះទៅរកសន្តិភាពសាកល សន្តិសុខរួម សណ្តាប់ធ្នាប់រួម និងតម្លៃរួមចំពោះសហអត្ថិភាព និងសុខដុមនៃមនុស្សជាតិទាំងមូល។

មានមូលដ្ឋានជាច្រើនក្នុងការលើកកម្ពស់សុខដុមនៃសង្គមមនុស្ស ប៉ុន្តែការស្រាវជ្រាវលើប្រធានបទនេះស្ថិតនៅក្នុងវង្វង់នៃការស្រាវជ្រាវមួយ ដែលផ្តេកជាសំខាន់ទៅលើតែការលើកកម្ពស់សុខដុមនីយកម្មនៃសង្គមមនុស្សតាមរយៈទស្សនវិជ្ជាសីលធម៌ គោលការណ៍រួម និងយន្តការរួមមួយចំនួនប៉ុណ្ណោះ។ ដូច្នេះ ទិន្នន័យ ឯកសារ និងបេកគំហើញនានាដែលទាក់ទងទៅនឹងការលើកកម្ពស់សុខដុមនីយកម្មនៅក្នុងសង្គមមនុស្សតាមរយៈទស្សនវិជ្ជាសីលធម៌ គោលការណ៍រួម និងយន្តការរួម គឺសុទ្ធតែជាកម្មវត្ថុនៃការស្រាវជ្រាវរបស់ប្រធានបទនេះ។ ហេតុនេះ យើងត្រូវប្រមូលឯកសារទាក់ទងនានា ដើម្បីអាននិងស្រង់យកទស្សនៈ បញ្ញត្តិ ទស្សនាទាន ទ្រឹស្តី និងការវិភាគនានាទាក់ទងទៅនឹងវិធី និងយន្តការផ្សេងៗ ដែលនាំសង្គមមនុស្សឆ្ពោះទៅរកសន្តិភាពសាកល សុខដុមនីយកម្មសាកល និងការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព។ លើសពីនេះទៀត ការស្រាវជ្រាវនេះក៏មានភារកិច្ចរិះគន់ វិភាគ និងវាយតម្លៃលើទស្សនៈ បញ្ញត្តិ ទស្សនាទាន និងទ្រឹស្តីទាំងឡាយដែលមានរួចមកហើយ ដោយឆ្លុះបញ្ចាំងទៅលើតថភាព និងសច្ចភាពក្នុងសង្គមមនុស្សទូទៅ និងសន្មត ឬស្នើឡើងនូវវិធីនិងយន្តការថ្មីៗមួយចំនួនដែលសង្គមមនុស្សអាចយកធ្វើជាមូលដ្ឋានក្នុងការលើកកម្ពស់សុខដុមនីយកម្មសាកល។

សុខដុមដែលការស្រាវជ្រាវនេះចង់ស្វែងរកនោះ គឺជាសុខដុមសម្រាប់សង្គមមនុស្សទូទៅ មិនមែនគ្រាន់តែជាសុខដុមសម្រាប់សង្គម ពិសេសណាមួយទេ។ ដូច្នេះ រាល់គំនិត ទស្សនៈ ទស្សនាទាន ទ្រឹស្តី ឬទស្សនវិស័យរបស់ទស្សនវិទូនានា អ្នកប្រាជ្ញនានា និងអ្នកស្រាវជ្រាវណាក៏ដោយក្នុងគ្រប់សម័យកាល ដែលទាក់ទងទៅនឹងការលើកកម្ពស់សុខដុមនីយកម្មនៅក្នុងសង្គមតាមរយៈទស្សនវិជ្ជាសីលធម៌ សុទ្ធសឹងជាកម្មវត្ថុនៃការស្រាវរបស់ប្រធានបទនេះ។

ការស្រាវជ្រាវលើប្រធានបទស្តីអំពី«ការលើកកម្ពស់ភាពសុខដុមនៃសង្គមមនុស្ស» ពិតជាអាចរួមចំណែកយ៉ាងសំខាន់ចំពោះសង្គមមនុស្ស ពីព្រោះវាព្យាយាមប្រមូលផ្តុំនូវរាល់គំនិត ទស្សនៈ ទស្សនាទាន ទ្រឹស្តី បទពិសោធន៍ គោលការណ៍ សច្ចភាព និងទស្សនវិស័យផ្សេងៗ ដែលទស្សនវិទូ អ្នកប្រាជ្ញ និង

ដល់មនុស្សនូវរបៀបដែលពួកគេគួរប្រព្រឹត្តផងដែរ។ ទស្សនវិជ្ជាសីលធម៌ទាក់ទងទៅនឹងការស្វែងរក និងការបង្ហាញនូវតម្លៃ។ តម្លៃគឺជាអ្វីដែលសំខាន់ និងជាគោលបំណងនៃការប្រព្រឹត្តិរបស់មនុស្ស។ ទស្សនវិជ្ជាសីលធម៌ត្រូវបានគេកំណត់និយមន័យថាជាការសិក្សាពីអ្វីដែលត្រូវ ឬខុសនៅក្នុងទង្វើរបស់មនុស្ស និងជាការស្វែងរកជីវិតប្រកបដោយកុសល។ វាជាការសិក្សាជាសំខាន់ទៅលើគោលការណ៍សីលធម៌ ច្បាប់នៃការប្រព្រឹត្តិ ឬប្រព័ន្ធផ្សេងៗ ដែលគួរត្រូវបានគេប្រព្រឹត្តតាមយ៉ាងហ្មត់ចត់។ វាកំណត់នូវអ្វីដែលជាការប្រព្រឹត្តិល្អ និងអ្វីដែលជាការប្រព្រឹត្តិមិនល្អ។ វាបង្ហាញនូវអំពើរបស់មនុស្ស ដែលគួរយល់ព្រម និងអំពើរបស់មនុស្សដែលមិនគួរយល់ព្រមតាម។ វាផ្តល់ឱ្យយើងនូវគំរូមួយ។ ផ្អែកលើមូលដ្ឋាននេះ យើងអាចដឹងថាតើអាកប្បកិរិយារបស់យើងប្រកបដោយសីលធម៌ ត្រឹមត្រូវ ប្រកបដោយគុណធម៌ និងគួរឱ្យចង់បាន ឬមិនគួរឱ្យចង់បាន។

ថ្វីបើមនុស្សម្នាក់ៗមានទម្លាប់ គុណធម៌ សីលធម៌ និងចំណង់ចំណូលចិត្តដោយឡែកៗពីគ្នាក៏ដោយ ក៏គេត្រូវតែគោរពនូវគោលការណ៍សីលធម៌រួម ដែលមានលក្ខណៈសាកលដែរ។ ដើម្បីមានភាពងាយស្រួលក្នុងការឈានទៅគោរពគោលការណ៍រួម គេគួរតែបណ្តុះស្មារតី ទម្លាប់ គុណធម៌ និងសីលធម៌ផ្ទាល់ខ្លួនរបស់គេ ដោយផ្អែកលើមូលដ្ឋានគោលការណ៍សីលធម៌រួម ឬសីលធម៌សាកល។ ប្រសិនបើធ្វើបែបនេះបាន នោះសង្គមមនុស្សទាំងមូលនឹងរកឃើញនូវចំណុចរួម ដែលអាចឈានទៅដល់ឯកភាព សន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ ការចុះសម្រុងគ្នា និងការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព។

បច្ចុប្បន្ននេះ មនុស្សភាគច្រើនលើសលប់បានដឹងថា ពិភពលោកកំពុងទទួលរងសម្ពាធកាន់តែខ្លាំងពីនយោបាយពិភពលោក បច្ចេកវិទ្យាពិភពលោក សេដ្ឋកិច្ចពិភពលោក និងអារ្យធម៌ពិភពលោក ដែលយើងពិតជាត្រូវការចាំបាច់នូវសីលធម៌ពិភពលោក ឬសីលធម៌សាកល ដើម្បីធ្វើឱ្យមានតុល្យភាពនៃចរន្តទាំងនេះ។ មធ្យោបាយនេះ មានន័យថាទស្សនៈ ឬសេចក្តីសម្រេចរួមជាមូលដ្ឋានដែលពាក់ព័ន្ធទៅនឹងការចងភ្ជាប់តម្លៃនានា មាត្រដ្ឋាន ឬគំរូដាច់ខាត និងឥរិយាបថបុគ្គល។ ប្រសិនបើគ្មានទស្សនៈ ឬសេចក្តីសម្រេចរួមជាមូលដ្ឋាននេះនៅក្នុងសីលធម៌ទេ នោះសង្គមមនុស្សនឹងត្រូវបំភិតបំភ័យយ៉ាងហ័សដោយភាពវឹកវរ ភាពច្របូកច្របល់ ឬអំណាចផ្តាច់ការ។ ក្នុងសភាពបែបនេះយើងអាចនិយាយថា មិនអាចមានសណ្តាប់សាកលល្អប្រសើរបានទេប្រសិនបើគ្មានសីលធម៌សាកល។

បញ្ញត្តិស្តីពីសាកលភាពនៃសីលធម៌ ឬសីលធម៌សាកល សំដៅទៅរកតម្លៃសីលធម៌រួមនិងគំរូសីលធម៌ ដែលផ្សំឡើងពីវប្បធម៌និងជំនឿផ្សេងៗនៅលើភពផែនដីនេះ។ តម្លៃសីលធម៌រួមនិងគំរូសីលធម៌ទាំងនេះបង្កើតបានជាសីលធម៌របស់មនុស្សជាតិ។ នៅក្នុងគំនិតស្តីពីដំណើរនៃសាកលភាវូបនីយកម្មសីលធម៌របស់មនុស្សជាតិ ដែលត្រូវបានកំណត់ដោយសាសនវិទូរ៉ូម៉ាំងកាតូលិក ជាសាស្ត្រាចារ្យ និងទស្សនវិទូដ៏ល្បីល្បាញម្នាក់ឈ្មោះ ហាន្ស គុង(Hans Kung) ថាជាសីលធម៌សាកល។ ទោះបីជាបញ្ញត្តិស្តីពីសីលធម៌សាកលបានបង្ហាញឱ្យស្គាល់ដោយសាស្ត្រាចារ្យ ហាន្ស គុង នៅក្នុងឆ្នាំ១៩៩៣ក៏ដោយ ក៏វាមិនមែនជាការបង្កើតថ្មីទេ វាគ្រាន់តែជាការរកឃើញនូវគោលការណ៍រួមដែលមានអាយុស្មើនឹងកំណើតរបស់មនុស្សជាតិប៉ុណ្ណោះ។

ប្រាកដណាស់ ពិភពលោកដែលកំពុងស្ថិតក្នុងសាកលភាវូបនីយកម្មនេះបានលេចឡើងនូវបញ្ហាជាច្រើន ដូចជា បញ្ហាសីលធម៌ បញ្ហាបរិស្ថាន និងបញ្ហាសង្គមជាច្រើនរាប់មិនអស់ ដែលយើងពិតជាត្រូវការចាំបាច់នូវសាកលភាវូបនីយកម្មនៃតម្លៃសីលធម៌រួមនិងគំរូសីលធម៌ ឬនិយាយឱ្យខ្លីថាសីលធម៌សាកល

ដើម្បីសង្គ្រោះជីវិតមនុស្សបច្ចុប្បន្ន និងកូនចៅរបស់យើងជំនាន់ក្រោយៗទៀតឱ្យរស់នៅបានសមរម្យ ថ្លៃថ្នូរ និងយូរអង្វែង។

យោងទៅតាម ហាន្ស គុង «សីលធម៌សាកល» មិនមានន័យថាជាមនោគមវិជ្ជាសាកល ឬសាសនាសាកល ឯកភាពតែមួយ ខ្ពស់ជាងសាសនាទាំងអស់ដែលកំពុងមានអត្ថិភាពនោះទេ ហើយវាក៏មិនមែនជាការបញ្ចូលគ្នានូវសាសនាទាំងអស់ដែរ។ គាត់បានបញ្ជាក់ម្តងហើយម្តងទៀតថា សីលធម៌សាកល មិនមែនមកជំនួសគម្ពីរសាសនា និងធម្មទេសនារបស់សាសនានានានោះទេ។ ផ្ទុយទៅវិញ «សីលធម៌សាកល» គ្មានអ្វីក្រៅពីអប្បបរមានៃតម្លៃរួម គំរូ ឬមាត្រដ្ឋានរួម និងឥរិយាបថមូលដ្ឋាននោះទេ។ម្យ៉ាងទៀត ការយល់ស្របជាមូលដ្ឋានកម្រិតអប្បបរមា ទាក់ទងទៅនឹងការចងភ្ជាប់តម្លៃផ្សេងៗ គំរូមិនអាចបដិសេធបាន និងឥរិយាបថសីលធម៌ ដែលអាចអះអាងទទួលស្គាល់ដោយសាសនាទាំងអស់ បើទោះបីជាមានភាពខុសគ្នាខាងគោលការណ៍របស់វា និងអាចគាំទ្រដោយអ្នកមិនជឿសាសនាក៏ដោយ។

តាមពិត ឫសគល់នៃការយល់ស្របជាមូលដ្ឋានពីតម្លៃ គំរូ ឬមាត្រដ្ឋាន និងឥរិយាបថ មានលក្ខណៈសាមញ្ញ ប៉ុន្តែវាសំខាន់បំផុត៖ «ចូរអ្នកប្រព្រឹត្តចំពោះអ្នកដទៃដូចដែលអ្នកចង់ឱ្យអ្នកដទៃប្រព្រឹត្តមកលើខ្លួនអ្នក»។ នេះជាអ្វីដែលគេហៅថាច្បាប់មាសនៃជីវិត ដែលគេបានរកឃើញនៅក្នុងគម្ពីរនៃជំនឿសាសនាសំខាន់ៗ ដែលពោលដោយពាក្យខុសៗគ្នា ប៉ុន្តែមានន័យដូចគ្នា។

ក្នុងបរិបទសង្គម ភាពចុះសម្រុងគ្នា ឬសុខដុម គឺជាសភាពមួយដែលប្រជាជនរស់នៅដោយសន្តិភាព សន្តិសុខនិងការស្រុះស្រួលគ្នា។ ឧទាហរណ៍៖ ការចុះសម្រុងខាងជាតិសាសន៍ គ្រួសារ សង្គម ឬការស៊ីសង្វាក់គ្នារវាងការអភិវឌ្ឍនិងអភិរក្ស ជាដើម។ ភាពចុះសម្រុងគ្នា ឬសុខដុមក្នុងចំណោមបុគ្គលនានា សំដៅទៅរកភាពសុខស្រួលដែលផ្សំឡើងដោយជីវិត តម្លៃ និងសកម្មភាពនានានៅក្នុងទំនាក់ទំនងរបស់ពួកគេ។ នៅពេលដែលជីវិតរបស់យើងចុះសម្រុងជាមួយមនុស្សជាតិទាំងអស់ មានន័យថា យើងកំពុងប្រព្រឹត្តក្នុងនាមជាផ្នែកមួយ ឬជាភ្នាក់ងារមួយនៃមនុស្សជាតិទាំងមូល។ យើងរួមចំណែកចំពោះសហគមន៍ទាំងមូល ឬប្រព័ន្ធទាំងមូល និងយើងធ្វើដូច្នោះដោយការប្រព្រឹត្តិអនុលោមទៅតាមវិចារណញ្ញាណបែបធម្មជាតិ។ យើងអាចទទួលបានសុខដុមពីអត្ថិភាពរបស់យើង នៅពេលណាដែលយើងរស់នៅអនុលោមតាមវិចារណញ្ញាណ និងរស់នៅដើម្បីផលប្រយោជន៍សម្រាប់ទាំងអស់គ្នា។

ឆ្លងតាមបទពិសោធន៍ក្នុងតថភាពសង្គម ប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ការគិត ការវិភាគ និងការសន្មត យើងបានដឹងថាការកសាងសុខដុមនីយកម្មផ្អែកលើមូលដ្ឋានមួយចំនួន ដូចជា ទស្សនវិជ្ជា សាសនា ទំនៀមទម្លាប់ ប្រពៃណី ច្បាប់ សិទ្ធិមនុស្ស សីលធម៌ និងនយោបាយ។ ជាតុនីមួយៗមានមុខងារសារសំខាន់ និងលក្ខណៈពិសេសរៀងៗខ្លួន។

ក្រៅពីនេះ សង្គមមនុស្សបានរិះរកមធ្យោបាយមួយចំនួនផ្សេងទៀត ដើម្បីទទួលបាននូវសុខដុមរមនាសាកលនេះ ដូចជា សីលធម៌ផ្លូវកណ្តាល សហព័ន្ធអន្តរសាសនាសាកលលោក សភាសាសនាសាកលលោក យន្តការអន្តរជាតិ អង្គការតំបន់និងពិភពលោក ច្បាប់អន្តរជាតិ និងភាពទន់ភ្លន់និងត្រឹមត្រូវខាងការទូត ជាដើម។ ប្រសិនបើគ្មានមូលដ្ឋានរួមដូចបានរៀបរាប់ខាងលើទេ សង្គមមនុស្សមិនអាចទទួលបានសុខដុមសាកលពេញលេញឡើយ។

បន្ទាប់ពីយើងបានឃើញអត្ថន័យ គោលការណ៍ និងមូលដ្ឋាននៃទ្រឹស្តីទស្សនវិជ្ជាសីលធម៌ សីលធម៌សាកល សុខដុម សារសំខាន់របស់វា និងការវិភាគស៊ីជម្រៅអំពីវិស័យទាំងនោះរួចមក យើង

សូមអំពាវនាវ និងជំរុញឱ្យមនុស្សជាតិទាំងអស់ក្នុងនាមបុគ្គល ក្នុងនាមសហគមន៍ និងក្នុងនាមស្ថាប័ន យកពួកវាមកធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការប្រព្រឹត្តិដោយផ្អែកលើសីលធម៌ផ្លូវកណ្ដាល។ សីលធម៌ផ្លូវកណ្ដាលជាបញ្ញត្តិសំខាន់មួយ ដែលត្រូវបានកំណត់ទស្សនាទានប្លែកៗគ្នាដោយទស្សនវិទូ សាសនវិទូ និងអ្នកប្រាជ្ញផ្សេងៗទៀត។ វាត្រូវបានគេរំលេចចេញជាបរិវាសព្ទខុសៗគ្នា និងត្រូវបានគេយកទៅប្រើក្នុងវិស័យជាច្រើន ដូចជា ការរស់នៅប្រចាំថ្ងៃ វិស័យនយោបាយ ការគ្រប់គ្រងសេដ្ឋកិច្ច ពាណិជ្ជកម្ម ការអប់រំ សាសនា។ល។ អត្ថន័យនិងការប្រើប្រាស់បញ្ញត្តិនេះ នឹងត្រូវបានលាតត្រដាងក្នុងរបកគំហើញនៃការស្រាវជ្រាវជាបន្តបន្ទាប់ដូចខាងក្រោម។

ជាទូទៅនៅក្នុងសង្គមខ្មែរ តិចឬច្រើនប្រជាជនបានដឹងអំពីបញ្ញត្តិផ្លូវកណ្ដាលនេះ ជាពិសេសពួកគេបានទទួលឥទ្ធិពលនៃផ្លូវកណ្ដាលនេះពីព្រះពុទ្ធសាសនា «កុំធូរពេក(វាមិនពីរោះ) តែកុំតឹងពេក(វាដាច់) ត្រូវរឹតឱ្យតឹងល្មម(ទើបវាពីរោះ)» នេះគឺជាការប្រកាន់គោលជំហរកណ្ដាលសម្រាប់ដឹកនាំជីវិតបុគ្គល ជីវិតគ្រួសារ និងជីវិតសង្គមតាមបែបព្រះពុទ្ធសាសនា។ ក្រៅពីនេះក្នុងការអប់រំណែនាំកូនចៅរបស់ខ្លួន ចាស់ទុំខ្មែរតែងតែបានលើកឡើងនូវពាក្យប្រៀនប្រដៅមួយចំនួនទៀតដែលជាប់ពាក់ព័ន្ធជាមួយផ្លូវកណ្ដាល។

ក្នុងទស្សនវិជ្ជា ផ្លូវកណ្ដាលត្រូវបានគេចាត់ទុកថាជាមធ្យោបាយមាស ជាពិសេស នៅក្នុងទស្សនវិជ្ជារបស់ អារីស្តូត មធ្យោបាយមាសគឺជាផ្លូវកណ្ដាលនៃសេចក្ដីប្រាថ្នា ដែលនៅចន្លោះភាពដាច់ខាតទាំងពីរ ទីមួយគឺភាពលើសកំណត់(លើសលប់) ទីពីរភាពទន់ខ្សោយ(ភាពមិនគ្រប់គ្រាន់)។ ក្រៅពីនេះ ក៏មានទស្សនវិទូមួយចំនួនទៀតបានលើកឡើងនូវទស្សនាទានរបស់ខ្លួនស្ដីអំពីផ្លូវកណ្ដាលនេះផងដែរ។

ផ្លូវកណ្ដាលគឺជាបញ្ញត្តិមួយ ដែលប្រើដោយព្រះពុទ្ធអង្គដើម្បីរៀបរាប់ពីលក្ខណៈនៃផ្លូវមួយដែលព្រះអង្គបានរកឃើញ ហើយផ្លូវនេះនាំទៅដល់ការរំដោះខ្លួនចេញពីទុក្ខទោសទាំងឡាយ។ ពាក្យនេះត្រូវបានប្រើក្នុងការបង្រៀនជាលើកដំបូងបំផុតបន្ទាប់ពីព្រះអង្គបានត្រាស់ដឹង។ ព្រះពុទ្ធពិពណ៌នាផ្លូវកណ្ដាលថាជាផ្លូវមួយនៅចន្លោះភាពដាច់ខាតនៃសេចក្ដីរីករាយខាងវិញ្ញាណ និងការបំបាក់មុខខ្លួនឯង។ យោងទៅតាមព្រះអង្គ ផ្លូវនេះគឺជាផ្លូវនៃគតិបណ្ឌិត។ ផ្លូវកណ្ដាលស្ថិតនៅខាងក្នុងស្មារតីរបស់មនុស្ស វាមិនមែនស្ថិតនៅខាងក្រៅក្នុងកម្មវត្ថុទេ។

ផ្លូវកណ្ដាលត្រូវបានគេទៅអនុវត្តនៅក្នុងវិស័យជាច្រើន និងរួមទាំងវិស័យអប់រំផងដែរ។ ផ្លូវកណ្ដាលនៅក្នុងការអប់រំជំរុញឱ្យការអប់រំមានតុល្យភាព។ ការអប់រំដែលមានតុល្យភាព គឺជាការអប់រំមួយដែលធ្វើឡើងស្របគ្នានិងសមាមាត្ររវាងការអប់រំចិត្ត ការអប់រំនិយាមសីលធម៌ និងការអប់រំអំណាច។

ផ្លូវកណ្ដាលក្នុងការគ្រប់គ្រងរដ្ឋសម្ដៅយកនយោបាយ ឬរបៀបនៃការគ្រប់គ្រងប្រទេស ដែលមិនធូររលុងពេក អាចនាំឱ្យមានភាពអនាធិបតេយ្យ ចលាចល ច្របូកច្របល់។ល។ ហើយក៏មិនតឹងតែងពេក ដែលអាចនាំទៅដល់ការបំបិទសិទ្ធិ សេរីភាព ឬពោរពេញដោយភាពផ្ដាច់ការដែរ។ លើសពីនេះទៀត យើងក៏ចង់បង្ហាញ ឬរកឱ្យឃើញនូវការគ្រប់គ្រងមួយដែលមិនគិតគូរ ឬឱ្យតម្លៃតែទៅលើផលប្រយោជន៍បុគ្គលហួសហេតុពេក ហើយក៏មិនគិតគូរតែផលប្រយោជន៍រួម ឬឱ្យតម្លៃតែទៅលើសង្គម ឬរដ្ឋហួសហេតុពេកដោយមិនបានគិតពីសេរីភាព សេចក្ដីថ្លៃថ្នូរ និងផលប្រយោជន៍បុគ្គលដែរ។ ពោលគឺយើងចង់បានការគ្រប់គ្រងប្រទេសមួយបែប ដែលមានតុល្យភាពរវាងផលប្រយោជន៍បុគ្គលនិងផលប្រយោជន៍សង្គម និងសមាមាត្ររវាងសេចក្ដីសុខរបស់បុគ្គលនិងសេចក្ដីសុខរបស់សង្គម។

ផ្លូវកណ្តាលក្នុងបរិបទពាណិជ្ជកម្មកំណត់ដោយសីលធម៌ពាណិជ្ជកម្ម។ គោលបំណងសំខាន់នៃសីលធម៌ពាណិជ្ជកម្ម គឺការតម្រង់ទិសជំនួញឱ្យឆ្ពោះទៅរកផ្លូវមួយត្រឹមត្រូវ ពោលគឺគ្រប់ទិដ្ឋភាពនៃឥរិយាបថជំនួញ រួមទាំងឥរិយាបថបុគ្គល និងស្ថាប័នពាណិជ្ជកម្មទាំងមូលឱ្យដើរស្របតាមគោលការណ៍សីលធម៌ និយាមសង្គម ច្បាប់ជាតិនិងច្បាប់អន្តរជាតិដើម្បីបង្ការនិងទប់ស្កាត់អំពើអសីលធម៌ អំពើល្មើសច្បាប់ អំពើអយុត្តិធម៌ ទំនាស់ផលប្រយោជន៍ ការបោកប្រាស់ និងឧក្រិដ្ឋកម្ម ដែលតែងតែកើតឡើងនៅក្នុងវិស័យពាណិជ្ជកម្ម ឬជំនួញនេះ។

ក្រៅពីយន្តការនានា និងសីលធម៌ផ្លូវកណ្តាល ដែលត្រូវបានគេប្រើសម្រាប់ធ្វើជាមូលដ្ឋានក្នុងការស្វែងរកសុខដុមនីយកម្មសាកល យើងក៏បានសង្កេតឃើញមានស្ថាប័នអន្តរជាតិជាច្រើនទៀត ដូចជា អង្គការសហប្រជាជាតិ អង្គការណាតូ សហភាពអឺរ៉ុប តុលាការយុត្តិធម៌អន្តរជាតិ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ស្ថានទូត អង្គការសិទ្ធិមនុស្ស សភាសាសនាពិភពលោក សហព័ន្ធសន្តិភាពសាកល រង្វាន់ណូបែលសន្តិភាព។ល។ ក៏ត្រូវបានគេអះអាងថាបង្កើតឡើងដើម្បីរួមចំណែកស្វែងរកសន្តិភាព ឬសុខដុមនីយកម្មសាកលដែរ។ ក្នុងយន្តការនីមួយៗយើងនឹងពិនិត្យមើល និងវិភាគបែបទស្សវិជ្ជាទៅលើតួនាទី មុខងារ យន្តការ បេសកកម្ម និងចក្ខុវិស័យនៃស្ថាប័ននីមួយៗក្នុងការរួមចំណែកស្វែងរកសន្តិភាព សន្តិសុខ និងសុខដុមនីយកម្មសាកល។

ដើម្បីធ្វើឱ្យមានសុខដុមនីកម្មនៅក្នុងសង្គមខ្មែរ យើងចាំបាច់ត្រូវចាប់ផ្តើមពីការធ្វើឱ្យមានការចុះសម្រុងនឹងបុគ្គលខ្លួនឯង ការចុះសម្រុងនៅក្នុងគ្រួសារ ស្ថាប័នរដ្ឋ វិស័យឯកជន អង្គការមិនមែនរដ្ឋ និងសង្គមស៊ីវិល វិស័យសាសនា និងគណៈបក្សនយោបាយ។ ឆ្លងតាមបេកគំហើញនៃការស្រាវជ្រាវយើងបានរកឃើញថា មានកត្តាជាច្រើនដែលជំរុញឱ្យសង្គមខ្មែរមានទំនាស់ហូតមកដល់ពេលនេះ។ កត្តាទាំងនោះរួមមានៈ ១.ជម្លោះក្នុងគ្រួសារ ២.ក្នុងសហគមន៍ ៣.ជម្លោះគណបក្សនយោបាយ ៤.ទំនាស់រវាងអ្នកដឹកនាំនិងអ្នកត្រូវគេដឹកនាំ ៥.ការមិនចុះសម្រុងគ្នាក្នុងចំណោមស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋកិបាលនិងវិស័យឯកជន ៦.ទំនាស់រវាងផលប្រយោជន៍រួមនិងផលប្រយោជន៍បុគ្គល ៧.យន្តការការលើកកម្ពស់សីលធម៌សង្គមនិងសិទ្ធិមនុស្សមិនទាន់រឹងមាំ ៨.ឥទ្ធិពលអវិជ្ជមាននៃសាកលភាវូបនីយកម្ម ៩.គម្លាតរវាងអ្នកមាននិងអ្នកក្រមានកម្រិតខ្ពស់ ១០.ភាពលម្អៀងក្នុងការអនុវត្តច្បាប់ ១១.ទំនាស់ក្នុងសេវាសាធារណៈ និង១២.អនុស្សាវរីយ៍ជូរចត់ក្នុងប្រវត្តិសស្ត្រ។

ឆ្លើយតបទៅនឹងមូលដ្ឋានទាំងដប់ពីរដែលនាំឱ្យសង្គមខ្មែរមានទំនាស់ ដូចបានរៀបរាប់ខាងលើ និងផ្អែកលើការវិភាគបែបទស្សនវិជ្ជា ក្នុងនាមអ្នកស្រាវជ្រាវយើងសូមលើកឡើងនូវវិធីមួយចំនួន ដែលអាចរួមចំណែកក្នុងការដោះស្រាយទំនាស់នានានៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។ វិធីទាំងនោះរួមមានៈ ១.ការធ្វើសុក្រឹតភាវូបនីយកម្មបុគ្គល ២.ការពង្រឹងតួនាទីគ្រួសារ ៣.ការពង្រឹងតួនាទីសាលារៀន ៤.ការពង្រឹងតួនាទីរបស់ស្ថាប័នរដ្ឋ ៥.ការតម្រង់ទិសប្រព័ន្ធផ្សព្វផ្សាយ ៦.ការតម្រង់ទិសគណបក្សនយោបាយ ៧.ការតម្រង់ទិសវិស័យឯកជន ៨.ការតម្រង់ទិសសង្គមស៊ីវិលនិងអង្គការក្រៅរដ្ឋាភិបាល ៩.ការតម្រង់ទិសស្ថាប័នសាសនា និង១០.ការលើកកម្ពស់វិស័យសប្បុរសធម៌។

មានន័យថា បុគ្គលម្នាក់ៗ គ្រួសារនីមួយៗ សហគមន៍នីមួយៗ ស្ថាប័នរដ្ឋ ស្ថាប័នសង្គមស៊ីវិល គណបក្សនយោបាយ វិស័យឯងជន វិស័យសាសនា ប្រព័ន្ធផ្សព្វផ្សាយ និងផ្នែកផ្សេងៗទៀតរបស់សង្គម ត្រូវតែរួមគ្នាលើកកម្ពស់ការគោរពច្បាប់ជាតិ ច្បាប់អន្តរជាតិ កិច្ចព្រមព្រៀងអន្តរជាតិ គោលការណ៍សិទ្ធិ

មនុស្ស សីលធម៌ផ្លូវកណ្ដាល និងសីលធម៌សាកល ដើម្បីស្វែងរកសុខដុមនីយកម្មក្នុងសង្គមខ្មែរនិងក្នុងពិភពលោកទាំងមូល។

ឆ្លងតាមការបង្ហាញ និងការវិភាគស៊ីជម្រៅក្នុងស្នាដៃស្រាវជ្រាវទាំងមូល យើងអាចនិយាយបានថា សង្គមមនុស្សទាំងមូលមានសក្ដានុពលជាច្រើន ដូចជា និយាមសង្គម ប្រព័ន្ធច្បាប់ ស្ថាប័នគ្រួសារ ស្ថាប័នសង្គម ស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងយន្តការជាច្រើនទៀត ដែលយើងអាចយកពួកវាធ្វើជាមធ្យោបាយក្នុងការឈានទៅសម្រេចភាពសុខដុមរមនាសម្រាប់សង្គមមនុស្សទាំងមូលបាន ប៉ុន្តែយើងត្រូវតែប្រើប្រាស់សក្ដានុពលទាំងនោះក្នុងវិធីត្រឹមត្រូវ បើពុំដូចនោះទេ យើងមិនអាចសម្រេចបានតាមគោលបំណងរបស់យើងឡើយ។

ទោះបីជាសង្គមមនុស្សទូទៅមានសក្ដានុពលយ៉ាងច្រើនអនេក ដូចជា និយាមសង្គមបែបបុរាណ និយាមសង្គមបែបទំនើប ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងយន្តការផ្សេងៗជាច្រើនទៀតដូចបានរៀបរាប់ខាងលើក៏ដោយ ក៏រហូតមកដល់បច្ចុប្បន្ននេះ ពិភពលោកទាំងមូលនៅតែមិនទាន់ទទួលបានសុខដុមរមនាពេញលេញនៅឡើយ។ យើងបានរកឃើញយ៉ាងច្បាស់ថា ការណ៍ដែលពិភពលោកនៅតែមិនទាន់ទទួលបានភាពសុខដុមរមនាពេញលេញនោះ គឺដោយសារតែនិយាមសង្គមនិងយន្តការនានា ដែលមានស្រាប់ទាំងនោះមិនផ្អែកលើវិចារណញ្ញាណពេញលេញ មិនផ្អែកលើផលប្រយោជន៍រួមរបស់ជាតិនិងពិភពលោកពិតប្រាកដ និងជាពិសេសមិនផ្អែកលើសាកលភាពនៃសីលធម៌ សីលធម៌ផ្លូវកណ្ដាល និងមិនផ្អែកលើគោលការណ៍សិទ្ធិមនុស្សដែលគេបានប្រកាសឱ្យប្រើជាសាកលនោះឯង។ លើសពីនេះទៀត បើទោះបីជាមានអ្នកដឹកនាំប្រទេសខ្លះ បានយល់ដឹងពីសារប្រយោជន៍របស់សាកលភាពនៃសីលធម៌ សីលធម៌ផ្លូវកណ្ដាល និងគោលការណ៍សិទ្ធិមនុស្សក៏ដោយ ក៏ពួកគេបានត្រឹមតែទទួលស្គាល់នៅលើក្រដាស ឬទទួលស្គាល់តែមាត់ប៉ុណ្ណោះ មិនទាន់បានបញ្ចូលខ្លឹមសារមូលដ្ឋាននៃនិយាមទាំងនេះទៅក្នុងច្បាប់ និងមនសិការរបស់ខ្លួនឱ្យបានច្រើនសមស្របនៅឡើយ។ ឯការអនុវត្តជាក់ស្ដែងវិញក៏នៅមិនទាន់មានលក្ខណៈខ្លាំងក្លាដែរ។ ដូច្នេះហើយ ទើបយើងសង្កេតឃើញអំពើអាក្រក់ច្រើនរាប់មិនអស់ ដូចជា អំពើហិង្សា អំពើអយុត្តិធម៌ អំពើផ្ដាច់ការ ការរំលោភបំពាន ភាពច្របូកច្របល់ ភេរវកម្ម សង្គ្រាម និងវិបត្តិសង្គមផ្សេងៗទៀតនៅតែបន្តកើតឡើង និងរាលដាលពាសពេញពិភពលោក ដែលបង្កនូវសោកនាកម្មជាច្រើនអនេកទៅលើប្រជាជនស្លូតត្រង់។ លើសពីនេះទៀត គម្លាតរវាងអ្នកមានទ្រព្យនិងអ្នកក្រទ្រព្យ គម្លាតរវាងអ្នកមានចំណេះដឹងនិងអ្នកគ្មានចំណេះដឹង គម្លាតរវាងអ្នកមានអំណាចនិងអ្នកគ្មានអំណាចកាន់តែធំទៅៗ ដែលអាចនាំទៅដល់ទំនាស់ផលប្រយោជន៍ វិសមភាពសង្គម ការបះបោរ ចលាចល និងការប្រព្រឹត្តិអំពើអាក្រក់ផ្សេងៗទៀត ដែលអាចកើតឡើងដោយស្មានមិនដល់។

យោងទៅតាមការវិភាគបែបទស្សនវិជ្ជា យើងពិចារណាថាសភាពបែបនេះ អាចបណ្ដាលមកពីកត្តាជាច្រើនដូចជា៖

- សមត្ថភាពនៃបញ្ញា ការពិចារណា ទេពកោសល្យ ការស្រាវជ្រាវ ការបង្កើតថ្មី របកគំហើញ និងបទពិសោធន៍របស់មនុស្សជាតិនៅមានកម្រិត ឯសេចក្ដីប្រាថ្នារបស់មនុស្សគ្មានព្រំដែន។
- មនុស្សមួយចំនួននៅតែបន្តយកវេទនារម្មណ៍ ការលោភលន់ អវិជ្ជា មហិច្ឆតា និងអាត្មានិយម ធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការប្រព្រឹត្តិរបស់ខ្លួន។

- យន្តការជាតិ និងយន្តការអន្តរជាតិនៅមានភាពទន់ខ្សោយដោយអន្លើ និងនៅមានភាពលម្អៀង។
- អ្នកវិទ្យាសាស្ត្រនានានៅតែបន្តផលិតអាវុធគ្រប់ប្រភេទសម្រាប់បំផ្លាញមនុស្សជាតិ
- ប្រទេសមហាអំណាច និងប្រទេសផលិតអាវុធយុទ្ធភណ្ឌនៅតែបន្តប្រើប្រាស់ប្រទេសនានាជាកម្មវត្ថុនៃផលប្រយោជន៍ខាងសេដ្ឋកិច្ច ឬជាទីផ្សារលក់អាវុធរបស់ខ្លួន។
- អ្នកនយោបាយមួយចំនួន នៅតែបន្តប្រើប្រាស់អំពើហិង្សាដើម្បីដោះស្រាយបញ្ហា
- អ្នកជំនួញមួយចំនួន នៅតែបន្តប្រព្រឹត្តអំពើសីលធម៌។
- មនុស្សមួយចំនួនមិនបានបណ្តុះសម្បជញ្ញៈ មនសិការ ទំនួលខុសត្រូវ និងកាតព្វកិច្ចសីលធម៌របស់ខ្លួនចំពោះសង្គមនៅឡើយ។
- ការរើសអើង ការខ្ជីដៃ ឬកម្លាំងគ្នាប្រើ
- ការខ្វះសហអត្ថិភាព ខ្វះការយោគយល់គ្នា និងខ្វះការអត់ឱន
- ភាពផ្ទុយគ្នាខាងទស្សនៈ ទស្សនាទាន បញ្ញត្តិ...ក្នុងការដោះស្រាយវិវាទ ការស្វែងរកសន្តិភាព សន្តិសុខ យុត្តិធម៌ សេរីភាព ការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព និងសុខដុមនីយកម្មសាកល។

ការស្វែងរកសុខដុមរមនាសម្រាប់មនុស្សជាតិទាំងមូល ពិតជាមានឧបសគ្គជាច្រើនអនេកមិនអាចគណនាបាន។ ប្រសិនបើយើងជាមនុស្សជាតិមិនរួបរួមគ្នារកវិធីដោះស្រាយវិបត្តិនេះទេ វានឹងនៅតែបន្តកើតមានដូចសព្វថ្ងៃ និងអាចធ្ងន់ធ្ងរជាងនេះផងក្នុងពេលអនាគត។ ជាការណ៍ពិតណាស់ ប្រសិនបើយើងរួបរួមគ្នា អ្វីៗជាច្រើនអនេកយើងពិតជាអាចធ្វើបាន ទោះបីជាមិនអាចសម្រេចបានភ្លាមៗក៏ដោយក៏វាអាចនឹងសម្រេចបាននៅពេលណាមួយក្នុងអនាគត។ ផ្តើមចេញពីគំនិតនេះ ក្នុងនាមអ្នកស្រាវជ្រាវខាងទស្សនវិជ្ជា យើងសូមចូលរួមចំណែកលើកឡើងនូវទស្សនៈអប្បបរមាស្តីពីដំណោះស្រាយវិបត្តិសង្គមមនុស្ស ដែលមានជាបន្តបន្ទាប់ដូចខាងក្រោម។

យើងសូមអំពាវនាវដល់មនុស្សជាតិទាំងអស់ ជាពិសេស ទស្សនវិទូ សាសនវិទូ អ្នកស្រាវជ្រាវ អ្នកនយោបាយ អ្នកដឹកនាំសង្គមស៊ីវិល វិស័យឯកជន និងសកម្មជនទាំងអស់ ដែលជាអ្នកស្រឡាញ់សន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ សមធម៌ អហិង្សា ការអភិវឌ្ឍរួមប្រកបដោយនិរន្តរភាព និងសុខដុមនីយកម្មសាកល ត្រូវតែរិះរកមធ្យោបាយនានាដើម្បីបញ្ចៀសពិភពលោកទាំងមូលឱ្យគេចផុតពីកត្តាអវិជ្ជមានដូចដែលបានរៀបរាប់ខាងលើ និងត្រូវចៀសឱ្យផុតពីអំពើអាក្រក់ទាំងឡាយ ជាពិសេសៈ

**ក) ត្រូវចៀសឱ្យផុតពីអំពើអាក្រក់ទាំងជប់ដែលប្រឆាំងទៅនឹងមនុស្សជាតិៈ**

1. ការធ្វើនយោបាយដោយគ្មានគោលការណ៍ត្រឹមត្រូវ
2. ការទទួលបានទ្រព្យសម្បត្តិដោយមិនធ្វើការងារ
3. ការសប្បាយរីករាយដែលគ្មានមនសិការ
4. ពុទ្ធិដែលគ្មានស្វ័យគ្រប់គ្រង(ខ្វះសីលធម៌)
5. ជំនួញដែលគ្មានសីលធម៌
6. វិទ្យាសាស្ត្រដែលមិនគិតពីសេចក្តីសុខរបស់មនុស្ស
7. សាសនាដែលគ្មានមេត្តាធម៌ ឬការអាណិតអាសូរ

8. សិទ្ធិដែលខ្វះទំនួលខុសត្រូវ
9. អំណាចដែលខ្វះកាតព្វកិច្ចទំនួលខុសត្រូវ(គណនេយ្យភាព)
10. ការអភិវឌ្ឍដែលគ្មាននិរន្តរភាព

ខ)ត្រូវយកចិត្តទុកដាក់លើដំណោះស្រាយមួយចំនួនទៀតដូចខាងក្រោម៖

1. ត្រូវជំរុញការអប់រំឱ្យមានតុល្យភាព
2. ជំរុញឱ្យបុគ្គល គ្រួសារ និងសង្គមមនុស្សទាំងមូល បណ្តុះសុចន្ទៈ បំណងល្អ មនសិការទំនួលខុសត្រូវ កាតព្វកិច្ច និងធ្វើសេចក្តីសម្រេចចិត្តប្រកបដោយគតិបណ្ឌិតសម្រាប់ខ្លួនឯងផង និងមនុស្សជាតិទាំងមូលផងក្នុងពេលជាមួយគ្នា។
3. តម្រង់ទិសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឱ្យឆ្ពោះរកផ្លូវល្អ
4. បង្កើនចំណេះដឹងទូទៅនិងចំណេះដឹងជំនាញចំពោះមនុស្សជាតិ
5. សិក្សា និងវាយតម្លៃនិយាមសង្គម និងច្បាប់នានា ដើម្បីរកឱ្យឃើញចំណុចរួម ចំណុចដោយឡែក ចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានក្នុងបំណងឈានទៅដកស្រង់យកជាតួរួមដែលមានតម្លៃសាកលទៅធ្វើជាមូលដ្ឋាននៃសីលធម៌សាកល ឬច្បាប់សាកល។
6. លើកកម្ពស់ការអប់រំ ការផ្សព្វផ្សាយ ការយល់ដឹង និងការអនុវត្តសិទ្ធិមនុស្ស សីលធម៌សាកល សីលធម៌ផ្លូវកណ្តាល ច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

គ)គួរចូលរួមគាំទ្រ លើកកម្ពស់ និងសម្រេចនូវឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ

លើសពីនេះទៅទៀត មនុស្សជាតិទាំងអស់ក្នុងនាមជាបុគ្គល ជាក្រុម ជាស្ថាប័ន និងក្នុងឋានៈជាអ្នកដឹកនាំនិងអ្នកត្រូវគេដឹកនាំទាំងអស់ ត្រូវតែចាំឱ្យច្បាស់ថា សេចក្តីសុខ សេចក្តីទុក្ខ និងដំណើរនៃជីវិតរបស់យើងក្នុងនាមជាមនុស្សជាតិ ពិតជាជាប់ទាក់ទងគ្នាជាបរានុម័តិ។ ជាការណ៍ពិតណាស់ បើទោះបីជាយើងបកស្រាយតាមបែបសាសនា ឬវិទ្យាសាស្ត្រក៏ដោយ ក៏អាចបញ្ជាក់បានថា កំណើតរបស់មនុស្សដំបូងមានប្រភពតែមួយ ពោលគឺត្រូវបានបង្កើតដោយអាទិទេព(បើយោងតាមទស្សនៈសាសនា) ឬដោយធម្មជាតិដែលបានវិវត្តមកពីសត្វស្វាម្យ៉ាង(តាមទស្សនៈវិទ្យាសាស្ត្រ)។ យោងតាមអំណះអំណាងនេះ យើងអាចនិយាយបានថា មនុស្សជាតិទាំងអស់នៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ មានអម្បូររួមគ្នា វង្សត្រកូលរួមគ្នា និងជាបងប្អូននឹងគ្នា។ ម្យ៉ាងទៀតមនុស្សជាតិមានលក្ខណៈរួមជាច្រើនទៀត ដូចជា សរីរធាតុដែលមានក្នុងរាងកាយរបស់មនុស្សមានប្រភេទដូចគ្នា មុខងាររបស់សរីរាង្គនិងអវយវៈទាំងអស់របស់មនុស្សមានលក្ខណៈដូចគ្នា ផ្នែកស្មារតី បាតុភូតចិត្ត អារម្មណ៍ និងវិចារណញ្ញាណមានលក្ខណៈដូចគ្នា ឯការឈឺចាប់ខាងផ្លូវកាយ និងការឈឺចាប់ខាងផ្លូវចិត្តក៏មានលក្ខណៈដូចគ្នាដែរ។

ក្រៅពីនេះ យើងទាំងអស់គ្នាត្រូវចងចាំថា យើងផឹកទឹកដែលមានសារធាតុ ឬរូបមន្តតែមួយ ($H_2O$) យើងដកដង្ហើមស្រូបយកខ្យល់អុកស៊ីហ្សែនដូចគ្នា យើងរស់នៅលើភពផែនដីតែមួយ យើងរស់នៅក្រោមមេឃតែមួយ និងយើងមានលក្ខណៈរួមជាច្រើនទៀត។ ដូចច្នេះ យើងពិតជាបងប្អូននឹងគ្នា

ហើយសុខទុក្ខរបស់ពួកយើងពិតជាជាប់ទាក់ទងគ្នាប្រាកដមែន។ ភស្តុតាងនៃសាកលភាវូបនីយកម្ម និងបម្រែបម្រួលប្រព័ន្ធបរិស្ថាន(ឬប្រព័ន្ធអេកូ)សាកល ពិតជាបានបញ្ជាក់យ៉ាងច្បាស់ថា ការប្រែប្រួលខាងធម្មជាតិ និងការប្រែប្រួលខាងសង្គម ពិតជាបានជាប់ទាក់ទងគ្នាជាបរានុម័តិដោយមិនអាចចៀសផុត។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា បញ្ហាទាំងអស់នៅក្នុងធម្មជាតិនិងសង្គមសុទ្ធតែជាប់ទាក់ទងគ្នា ហេតុនេះ បើចង់ដោះស្រាយករណីដោយឡែក គេត្រូវតែដោះស្រាយករណីរួមផងដែរ ហើយបើចង់ដោះស្រាយករណីរួមវិញគេក៏ត្រូវដោះស្រាយករណីដោយឡែកក្នុងពេលជាមួយគ្នាដែរ។ ពោលគឺត្រូវដោះស្រាយបញ្ហាជាកញ្ចប់ក្នុងពេលជាមួយគ្នា ទើបអាចដោះស្រាយបញ្ហាពិភពលោកបាន។

